# សម្រង់សារព័ត៌មានថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧

១.គេហទំព័រ Bangkokpos

## *Japanese who restored Angkor Wat wins Magsaysay Award*

27 Jul 2017 at 18:26 WRITER: KYODO NEWS (bangkokpos)



MANILA - A former president of Japan's Sophia University was named on Thursday as one of six recipients of this year's Ramon Magsaysay Awards, also known as the Asian Nobel Prize.

In a statement, the Ramon Magsaysay Award Foundation said Yoshiaki Ishizawa is being recognised for his efforts to restore Cambodia's cultural monuments such as Angkor Wat.

The other recipients are Abdon Nababan of Indonesia, Gethsie Shanmugam of Sri Lanka, Tony Tay of Singapore, and Lilia de Lima and the Philippine Educational Theater Association of the Philippines.

"The Magsaysay awardees of 2017 are all transforming their societies through their manifest commitment to the larger good," foundation president Carmencita Abella said in the statement.

According to the foundation, Ishizawa, 79, "devoted 50 years of his life to help assure that Angkor Wat survives and remains a living monument for Cambodians." The 162.6-hectare temple complex, the world's largest religious monument, dates back to the 12th century.

Ishizawa began his involvement in the conservation effort when he first visited Angkor Wat in 1961 as a student, and he was instrumental in the 1989 launch of the Sophia University Angkor International Mission.

Nababan, 53, was awarded the honour for his advocacy on behalf of Indonesia's indigenous communities, the foundation said.

Shanmugam, 82, was recognised for her efforts over four decades in building Sri Lanka's capacity for psychosocial support.

Singapore's Tay in 2003 organised "Willing Hearts," a volunteer-based, nonprofit organisation, to distribute hot meals to the needy, inspired by his late mother's charity work.

The Philippines' Lilia de Lima is being honoured for her leadership and building of the Philippine Economic Zone Authority from 1995 to 2015.

The Philippine Educational Theater Association was recognised for its "bold, collective contributions in shaping the theater arts as a force for social change."

The awardees will receive a certificate, a medallion, and a cash prize during a formal ceremony in Manila on Aug 31.

At the awards ceremony, the recipients will receive a certificate, a medallion bearing the image of Magsaysay, and a cash prize. The 2017 recipients join 318 other Magsaysay laureates.

The award was created in 1957 in honour of former Philippine president Ramon Magsaysay, a figure known for his selfless service. He died in a plane crash in the central Philippines in 1957.

**៦.គេហទំព័រ** The Phnom Penh Post

### *Angkor Wat advocate awarded 'Asia's Nobel'*

Fri, 28 July 2017 AFP(The Phnom Penh Post)

A Japanese historian who helped save Cambodia's renowned Angkor Wat temple complex was among the winners of this year's Magsaysay Awards, widely regarded as Asia's version of the Nobel Prize, organisers said yesterday.

Yoshiaki Ishizawa, 79, was honoured for decades of work in helping preserve the historic landmark after the 12th-century temple complex barely survived years of war and civil strife, the award foundation said.

Aside from rallying international support to preserve the structures, the Japanese scholar was also cited for raising awareness among Cambodians of Angkor Wat's importance to their heritage.

"The protection and restoration of the sites of Cambodia should be carried out by the Cambodians, for the Cambodians," the award foundation quoted him as saying.

The Philippine Educational Theater Association was also honoured for 50 years of work in developing a national theatre, staging "protest" plays during the dictatorship of the late President Ferdinand Marcos and helping other Southeast Asian countries use the arts to advocate for issues related to sexuality, HIV/AIDs and gender.

Gethsie Shanmugam, 83, a Tamil psychological counsellor, also received the award for addressing emotional damage, particularly among women and children, who suffered from violence and disasters in her native Sri Lanka.

Her work covered the brutal Sinhalese-Tamil civil war and the 2004 tsunami, the foundation noted.

Indonesian Abdon Nababan, 53, also received the award for organising indigenous people in his country to assert their rights on issues like the forest lands in their territories.

Tony Tay, 70, received the award for addressing the unseen plight of the poor in wealthy Singapore, setting up "Willing Hearts", in 2003, a charity that distributed packed meals to the needy and has since branched out to providing optical and dental care.

Lawyer Lilia de Lima, 76, was cited for her leadership of a government agency overseeing the Philippines' export processing zones, turning the overstaffed, inefficient institution into one that has won widespread respect while boosting exports and attracting investments, the foundation said.

The Manila-based Ramon Magsaysay Award, named after a Filipino president killed in a plane crash, was established in 1957 to honour people and groups tackling development problems in Asia.

**៣.គេហទំព័រ** cambodiasymbolofchange

### *ជនជាតិជប៉ុនម្នាក់ឈ្នះពានរង្វាន់ណូបែលអាស៊ីដោយសារតែខិតខំអភិរក្សប្រសាទអង្គររបស់ខ្មែរ*

By សហការី - July 28, 2017 (cambodiasymbolofchange)



(ទីក្រុងប៉ារីស)៖ ប្រវត្តិវិទូជនជាតិជប៉ុន និងជាអតីតសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ Sophia របស់ប្រទេសជប៉ុន ត្រូវបានគេដាក់ឈ្មោះក្នុងបញ្ជីរាយនាមអ្នកទទួលពានរង្វាន់ Ramon Magsaysay ឆ្នាំទី៦ ដែលត្រូវបានគេស្គាល់ថាជាពានរង្វាន់ណូបែលទ្វីបអាស៊ី ។

នៅក្នុងសេចក្តីថ្លែងការណ៍របស់មូលនិធិ Ramon Magsaysay លោក Yoshiaki Ishizawa ត្រូវបានទទួលស្គាល់ចំពោះកិច្ចប្រឹងប្រែងរបស់លោក ក្នុងការស្តារបូជនីយដ្ឋានវប្បធម៌របស់កម្ពុជាដូចជាប្រាសាទអង្គរវត្តជាដើម ។

លោក Yoshiaki Ishizawa អាយុ ៧៩ឆ្នាំ ជាអ្នកស្រាវជ្រាវប្រវត្តិសាស្រ្តអាស៊ីអាគ្នេយ៍បានចំណាយពេល៥០ឆ្នាំ ដើម្បីជួយអភិរក្សប្រាសាទអង្គរវត្តរបស់ប្រទេសកម្ពុជាដែលមានទំហំ១៦២ហិចតា

ក្រោយពីប្រាសាទដ៏ល្អឯកនេះបានទទួលរងការបំផ្លិចបំផ្លាញក្នុងពេលវេលាមានជម្លោះ ជាពិសេសនៅសម័យខ្មែរក្រហមដែលមានរយៈពេល៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ។ លោក Ishizawa បានធ្វើទស្សនកិច្ចជាលើកដំបូងនៅអង្គរវត្តនៅឆ្នាំ១៩៦១ ក្នុងនាមជានិស្សិតម្នាក់ ។

អ្នកទទួលផ្សេងទៀតគឺ Abdon Nababan មកពីប្រទេសឥណ្ឌូនេស៊ី Gethsie Shanmugam មកពីប្រទេសស្រីលង្កាលោក Tony Tay នៃប្រទេសសិង្ហបុរី និង Lilia de Lima រួមជាមួយសមាគមមហោស្រពអប់រំភីលីពីននៃប្រទេសហ្វីលីពីន ។

លោកស្រី Carmencita Abella ប្រធានមូលនិធិ Ramon Magsaysay បានឱ្យដឹងនៅក្នុងសេចក្ដីថ្លែងការណ៍ថា៖ «អ្នកឈ្នះរង្វាន់ Magsaysay ឆ្នាំ២០១៧ ទាំងអស់ បានផ្លាស់ប្ដូរសង្គមតាមរយៈការប្ដេជ្ញាចិត្តជាក់ស្ដែងរបស់ពួកគេទៅនឹងផលប្រយោជន៍ដ៏ធំ» ៕

**៤.គេហទំព័រ** CEN

## *១.មន្ត្រីបុគ្គលិកបច្ចេកទេសអាជ្ញាធរជាតិអប្សរា២៣នាក់ បានបញ្ចប់វគ្គបណ្ដុះបណ្ដាលភាសាអង់គ្លេសក្រោមកិច្ចសហការពីស្ថានទូតអាមេរិក*

(ថ្ងៃទី 28 កក្កដា 2017, ម៉ោង 04:17:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)

ភ្នំពេញ: ការបណ្ដុះបណ្ដាលភាសាអង់គ្លេសដល់មន្ត្រីបុគ្គលិកបច្ចេកទេស ដែលរៀបចំដោយអាជ្ញាធរជាតិអប្សរា សហការជាមួយស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា គាំទ្រដោយគម្រោង English Language Fellow Programs បានបិទបញ្ចប់ និងប្រគល់វិញ្ញាបនបត្រនៅថ្ងៃព្រហស្បតិ៍ ទី ២៧ ខែកក្កដា ឆ្នាំ២០១៧នេះ ក្រោមអធិបតីភាពឯកឧត្តម ហង់ ពៅ អគ្គនាយករងអាជ្ញាធរជាតិអប្សរា។

វគ្គបណ្ដុះបណ្ដាលភាសាអង់គ្លេសជំនាញទំនាក់ទំនងទូទៅ និងជំនាញសរសេរនេះ ចាប់ផ្ដើមពីខែតុលា ឆ្នាំ២០១៦ ដល់ខែ កក្កដា ឆ្នាំ២០១៧នេះ ចែកជា៣វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន២៣នាក់ ក្នុងនេះមានស្រីចំនួន១០នាក់ មកពីនាយកដ្ឋានចំនួន៨ផ្សេងគ្នានៃអាជ្ញាធរជាតិអប្សរា។

ក្នុងឱកាសប្រគល់វិញ្ញាបនបត្រនេះ លោកស្រី Monica Davis មន្ត្រីកិច្ចការវប្បធម៌ស្ថានទូតអាមេរិកបានមានប្រសាសន៍ថា «ខ្ញុំសូមកោតសរសើរចំពោះអ្នកទាំងអស់គ្នា ខ្ញុំគិតថាការធ្វើការបណ្ដើររៀនបណ្ដើរ មិនមែនជាការងាយស្រួលទេ។ ខ្ញុំសង្ឃឹមថាទាំងអស់គ្នានឹងយកចំណេះដឹងទាំងនេះទៅបម្រើក្នុងវិស័យផ្សេងៗ ដែលជាប្រយោជន៍ដល់ប្រទេសកម្ពុជាផ្ទាល់»។

«អ្នកចេះភាសាអង់គ្លេសប្រៀបដូចជាមានប៉ាស្ព័រសម្រាប់ឆ្លងដែនឬមានអាវុធសម្រាប់ប្រយុទ្ធ»នេះបើតាមប្រសាសន៍ឯកឧត្តម ហង់ ពៅ ក្នុងឱកាសនៃពិធីបិទវគ្គបណ្ដុះបណ្ដាលនេះ។ ឯកឧត្តមមានប្រសាសន៍បន្តថា « យើងត្រូវធ្វើការប្រកួតប្រជែងការងារ ដូច្នេះភាសាអង់គ្លេសជាមធ្យោបាយយ៉ាងសំខាន់សម្រាប់ខ្លួនយើង។ អង់គ្លេសជាភាសាសំខាន់ និងសំខាន់សម្រាប់រយៈពេលយូរអង្វែង។ ខ្ញុំចង់ឱ្យយើងទាំងអស់គ្នាជាខ្មែរ ប្រើភាសាអង់គ្លេសដើម្បីពន្យល់ជនបរទេសឱ្យយល់ពីវប្បធម៌ខ្មែរជាជាងឱ្យជនបរទេសពន្យល់ជនបរទេសអំពីវប្បធម៌ខ្មែរ»។

កញ្ញា ម៉ៅ ជូណា ជាសិក្ខាកាមមួយរូប បានបង្ហាញនូវទឹកចិត្តរីករាយចំពោះការបណ្តុះបណ្តាលនេះ ថា «ខ្ញុំពិតជារំភើបណាស់ចំពោះការបណ្តុះបណ្តាលមួយនេះ។ វាពិតជាធ្វើឱ្យយើងបានទទួលនូវបទពិសោធន៍ថ្មីៗ ធ្វើឱ្យយើងក្លាហាន។ ពិសេសគឺយើងមានការអភិវឌ្ឍលឿនបំផុត ស្ទើរនឹកស្មានមិនដល់»៕

## *២.ប្រតិភូអាស៊ាន-ចិនផ្នែកអភិវឌ្ឍជនបទបំពេញទស្សនកិច្ចនៅភូមិធម្មជាតិរុនតាឯក*

(ថ្ងៃទី 27 កក្កដា 2017, ម៉ោង 05:57:PM) I ដោយ: អាជ្ញាធរជាតិអប្សរា(CEN)



សៀមរាប: ក្រោយចំណាយពេលប្រជុំ២ថ្ងៃនៅក្រុងសៀមរាប ថ្នាក់ដឹកនាំនៃកិច្ចប្រជុំអាស៊ាន-ចិនផ្នែកអភិវឌ្ឍន៍ជនបទរួមនឹងសមាជិកប្រមាណជិត១០០នាក់ បានទៅបំពេញទស្សនកិច្ចភូមិធម្មជាតិរុនតាឯកដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី២៧ខែកក្កដាឆ្នាំ២០១៧។

ដំណើរទស្សនកិច្ចនេះ ត្រូវបានសហការរៀបចំដោយអាជ្ញាធរជាតិអប្សរានិងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប។ លោក ខេង ញ៉ុល ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប ដែលចូលរួមក្នុងកម្មវិធីនេះបញ្ជាក់ថា ការមកទស្សនកិច្ចនៅភូមិធម្មជាតិរុនតាឯកពេលនេះ គឺដើម្បីឲ្យក្រុមប្រតិភូបានស្វែងយល់អំពីគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក ដែលអាជ្ញាធរជាតិអប្សរាកំពុងតែរៀបចំអភិវឌ្ឍន៍ទាំងផ្នែកកសិកម្ម និងទេសចរណ៍ ក្នុងគោលបំណងលើកស្ទួយជីវភាពប្រជាជនក្នុងមូលដ្ឋាន។

លោកបន្ថែមថា ក្រុមប្រតិភូពិតជាពេញចិត្តនឹងការរៀបចំភូមិដ្ឋាននេះដែលមានសណ្តាប់ធ្នាប់ល្អ និងបរិស្ថានស្រស់ស្អាតគួរឲ្យទាក់ទាញ។ ជាពិសេស ពួកគាត់ពិតជារីករាយដែលបានចូលរួមដាំដើមឈើអនុស្សាវរីយ៍នៅភូមិនេះទៀតផង ដែលជាផ្នែកមួយជួយបង្កើនគម្របព្រៃឈើនៅតំបន់នេះឲ្យកាន់តែមានភាពទាក់ទាញ ដែលអាចនឹងធ្វើឲ្យពួកគាត់ចង់វិលត្រឡប់មកទស្សនាលើកក្រោយៗទៀត។

ឯកឧត្តម ម៉ី ម៉ារ៉ាឌី ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងជាប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក បានធ្វើបទបង្ហាញសង្ខេបជូនប្រតិភូអំពីគោលបំណងនៃការបង្កើតភូមិធម្មជាតិរុនតាឯក ពិសេសការផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋពីតំបន់រមណីយដ្ឋានអង្គរ និងការអភិវឌ្ឍភូមិធម្មជាតិនេះដោយផ្តោតសំខាន់លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងវិស័យកសិកម្ម និងវិស័យទេសចរណ៍ ដើម្បីបង្កើនភាពងាយស្រួល និងចំណូលដល់ជីវភាពរបស់ប្រជាពលរដ្ឋនៅទីនេះ។

ជាមួយគ្នានេះ ឯកឧត្តមក៏បានអំពាវនាវដល់គ្រប់បណ្តាប្រទេសអាស៊ាននិងចិន ដើម្បីចូលរួមចំណែកលើការអភិវឌ្ឍភូមិធម្មជាតិនេះតាមគ្រប់មធ្យោបាយដែលអាចជួយបាន ដើម្បីអភិវឌ្ឍភូមិធម្ម

ជាតិនេះឲ្យកាន់តែរីកចម្រើន។ ជាពិសេស គឺការអភិវឌ្ឍផ្នែកកសិកម្ម និងទេសចរណ៍ ដែលជាគោលដៅដ៏សំខាន់នៃគម្រោងលើកស្ទួយជីវភាពប្រជាពលរដ្ឋនៅទីនេះ។

សូមបញ្ជាក់ថា ក្នុងដំណើរទស្សនកិច្ចនេះ ក្រៅពីការទស្សនាភូមិដ្ឋានប្រជាពលរដ្ឋ និងគម្រោងផ្សេងៗ ក្រុមប្រតិភូក៏បានទិញទំនិញធម្មជាតិរបស់អ្នកភូមិដូចជា បន្លែធម្មជាតិ តែម្ទូរល្មម និងផលិតផលផ្លែម្រុំជាដើម ដែលជាផលិតផលផ្ទាល់របស់អ្នកភូមិ ជាផលិតធម្មជាតិ គ្មានជាតិគីមី៕

**៥.គេហទំព័រ** Fresh news

## *ប្រតិភូអាស៊ាន-ចិន ផ្នែកអភិវឌ្ឍជនបទប្រមាណ១០០នាក់ មកបំពេញទស្សនកិច្ចភូមិធម្មជាតិរុនតាឯក ខេត្តសៀមរាប*

28/07/2017(Fresh news)



(សៀមរាប)៖ ក្រោយចំណាយពេលប្រជុំ២ថ្ងៃ នៅក្រុងសៀមរាប ថ្នាក់ដឹកនាំនៃកិច្ចប្រជុំអាស៊ាន-ចិន ផ្នែកអភិវឌ្ឍន៍ជនបទរួមនឹងសមាជិក ប្រមាណ១០០នាក់ បានទៅបំពេញទស្សនកិច្ចភូមិធម្មជាតិរុនតាឯក ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដំណើរទស្សនកិច្ចនេះ ត្រូវបានសហការរៀបចំដោយអាជ្ញាធរជាតិអប្សរា និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧។

លោក ខេង ញ៉ុល ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បានថ្លែងថា ការមកទស្សនកិច្ចនៅភូមិធម្មជាតិរុនតាឯក ពេលនេះគឺដើម្បី ឲ្យក្រុមប្រតិភូ បានស្វែងយល់អំពី គម្រោងអភិវឌ្ឍ ភូមិធម្មជាតិរុនតាឯក ដែលអាជ្ញាធរជាតិអប្សរា កំពុងតែរៀបចំអភិវឌ្ឍន៍ទាំងផ្នែកកសិកម្ម និងទេសចរណ៍ ក្នុងគោលបំណងលើកស្ទួយជីវភាព ប្រជាជនក្នុងមូលដ្ឋាន។

លោក ខេង ញ៉ុល បានបន្តថា ក្រុមប្រតិភូពិតជាពេញចិត្តនឹងការរៀបចំភូមិដ្ឋាននេះដែលមានសណ្ដាប់ធ្នាប់ល្អ និងបរិស្ថានស្រស់ស្អាតគួរ ឲ្យទាក់ទាញ។ ជាពិសេស ពួកគាត់ពិតជារីករាយដែលបានចូលរួមដាំដើមឈើអនុស្សាវរីយ៍នៅភូមិនេះទៀតផងដែល ជាផ្នែកមួយជួយ បង្កើនគម្របព្រៃឈើនៅតំបន់នេះឲ្យកាន់តែមានភាពទាក់ទាញ ដែលអាចនឹងធ្វើឲ្យពួកគាត់ចង់វិលត្រឡប់មកទស្សនាលើកក្រោយៗ ទៀត។

លោក ម៉ី ម៉ារ៉ាឌី ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងជាប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក បានធ្វើបទបង្ហាញសង្ខេបជូនប្រតិភូ អំពីគោលបំណង នៃការបង្កើតភូមិធម្មជាតិរុនតាឯក ពិសេសការផ្លាស់ប្ដូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋពីតំបន់រមណីយដ្ឋានអង្គរ និងការអភិវឌ្ឍភូមិធម្មជាតិនេះ ដោយផ្ដោតសំខាន់លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងវិស័យកសិកម្ម និងវិស័យទេសចរណ៍ ដើម្បីបង្កើនភាពងាយស្រួល និងចំណូលដល់ជីវភាព របស់ប្រជាពលរដ្ឋនៅទីនេះ។

ជាមួយគ្នានេះលោក ក៏បានអំពាវនាវដល់គ្រប់បណ្តាប្រទេសអាស៊ាន ចិន ដើម្បីចូលរួមចំណែកលើការអភិវឌ្ឍភូមិធម្មជាតិនេះតាម គ្រប់មធ្យោបាយ ដែលអាចជួយបានដើម្បីអភិវឌ្ឍភូមិធម្មជាតិនេះឲ្យកាន់តែរីកចម្រើនជាពិសេស គឺការអភិវឌ្ឍផ្នែកកសិកម្ម និងទេសចរណ៍ ដែលជាគោលដៅដ៏សំខាន់ នៃគម្រោងលើកស្ទួយជីវភាពប្រជាពលរដ្ឋនៅទីនេះ។

សូមបញ្ជាក់ថា ក្នុងដំណើរទស្សនកិច្ចនេះ ក្រៅពីការទស្សនាភូមិដ្ឋានប្រជាពលរដ្ឋ និងគម្រោងផ្សេងៗ ក្រុមប្រតិភូក៏បានទិញទំនិញធម្មជាតិរបស់អ្នកភូមិដូចជា បន្លែធម្មជាតិតែម្ទូរល្មមនិងផលិតផលផ្លែម្រុំជាដើមដែលជាផលិតផលផ្ទាល់ របស់អ្នកភូមិជាផលិតធម្មជាតិ គ្មានជាតិគីមី៕